ព្រះអម្ចាស់យេស៊ូវគ្រីស្ទ នឹងយាងត្រឡប់មកផែនដីវិញជាឆាប់ ។ នេះគឺជាព្រះបន្ទូលដែលទ្រង់បានសន្យាកាលដែលទ្រង់នៅមានព្រះជន្មលើផែនដីកាលពី ២០០០ (ពីរពាន់) ឆ្នាំមុន (យ៉ូហាន ១៤:១-៣) ។ តើយើងអាចដឹងពិតថា ព្រះអង្គនឹងយាងត្រឡប់មកវិញជាប្រាកដយ៉ាងដូចម្តេច? ចូរអាននូវបទទំនាយដែលព្រះអម្ចាស់យេស៊ូវ ទ្រង់មានបន្ទូលទុកជាមុនដោយផ្ទាល់ព្រះអង្គថា ការនេះនឹងកើតឡើងនៅគ្រាចុងក្រោយ ។ការអានបទគម្ពីរទាំងនេះដោយយកចិត្តទុកដាក់ ហើយប្រៀបធៀបបទគម្ពីរនេះទៅនឹងព្រឹត្តិការណ៍ដែលកំពុងកើតឡើងនៅក្នុងពិភពលោកសព្វថ្ងៃនឹងបញ្ជាក់ឲ្យឃើញថា ព្រះអម្ចាស់យេស៊ូវនឹងយាងមកវិញជាប្រាកដនៅសម័យយើងនេះ ។

## 1 ការបំផ្លាញព្រះវិហារ

កាលកំពុងតែយាងចេញពីព្រះវិហារមក នោះពួកសិស្សទ្រង់ម្នាក់ទូលថា “លោកគ្រូ មើលន៍ ថ្ម ហើយនឹងមន្ទីរ ល្អណាស់ហ្ន៎ ។ ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា “តើឃើញមន្ទីរធំទាំងនេះឬទេ? បន្តិចទៀតនឹងគ្មានថ្មនៅត្រួតលើថ្ម ដែលមិនត្រូវទម្លាក់ចុះនោះទេ (ម៉ាថាយ ២៤:១-២ ម៉ាកុស ១៣:១-២ លូកា ២១:៥-៦) ។ **ខគម្ពីរនេះត្រូវបានសម្រេចតាមន័យត្រង់នៅគ.សឆ្នាំ ៧០ ។**

## 2 ទីសម្គាល់នៃការយាងមកវិញ

រួចកាលទ្រង់គង់លើភ្នំដើមអូលីវទល់មុខនឹងព្រះវិហារ នោះ ពេត្រុស យ៉ាកុប យ៉ូហាន និងអន់ទ្រេ គេមកទូល សួរទ្រង់ដោយឡែកថា “សូមប្រាប់យើងខ្ញុំ តើកាលណាបានការទាំងនេះនឹងមកដល់ តើមានទីសម្គាល់ណាឲ្យដឹង ក្នុងកាលដែលការទាំងនេះជិតកើតមក? (ម៉ាថាយ ២៤:៣ ម៉ាកុស ១៣:៣-៤ លូកា ២១:៧)

## 3 នឹងមានមនុស្សបោកបញ្ឆោតជាច្រើន

ព្រះយេស៊ូវចាប់តាំងមានព្រះបន្ទូលឆ្លើយទៅគេថា “ចូរប្រយ័ត្ន ក្រែងអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេង ត្បិតនឹងមានមនុស្សជាច្រើនយកឈ្មោះខ្ញុំមកនិយាយថា គឺខ្ញុំនេះហើយ គេក៏នឹងនាំមនុស្សជាច្រើនឲ្យវង្វេងផង ។ (ម៉ាថាយ ២៤:៤-៥ ម៉ាកុស ១៣:៥-៦ លូកា ២១:៨)

## 4 ចម្បាំង និងសូរចម្បាំង

កាលណាអ្នករាល់គ្នាឮនិយាយពីចម្បាំងហើយពីសូរ ចម្បាំង នោះកុំឲ្យអ្នករាល់គ្នាមានចិត្តថប់បារម្ភឡើយ ត្បិតការទាំងនោះត្រូវតែមកដល់ តែពុំទាន់ដល់ចុងក្រោយបំផុតនៅឡើយទេ ។ (ម៉ាថាយ ២៤:៦ ម៉ាកុស ១៣:៧ លូកា ២១:៩)

## 5 ចម្បាំងរវាងពូជសាសន៍នានា រញ្ជួយដី គ្រោះទុរភិក្ស ជម្ងឺផ្សេងៗ

ទ្រង់ក៏មានព្រះបន្ទូលទៅគេថា “សាសន៍១នឹងលើកគ្នាទាស់នឹងសាសន៍១ ហើយនគរ១ទាស់នឹងនគរ១ ក៏នឹងមានកក្រើកដីជាខ្លាំង និងអំណត់ហើយអាសន្នរោគនៅកន្លែងផ្សេងៗ ទាំងមានហេតុនាំឲ្យភ័យ និងទីសម្គាល់យ៉ាងធំពីលើមេឃផង (ម៉ាថាយ ២៤:៧ ម៉ាកុស ១៣:៨ លូកា ២១:១០-១១) ។

## 6

តែការទាំងនេះ ជាដើមចមនៃសេចក្តីទុក្ខទេ (ម៉ាថាយ ២៤:៨ ម៉ាកុស ១៣:៨) ។

## 7 ការបៀតបៀនដល់គ្រីស្ទបរិស័ទ

តែមុននឹងការនេះកើតឡើង គេនឹងចាប់អ្នករាល់គ្នាធ្វើទុក្ខ បញ្ជូនទៅសាលាប្រជុំហើយដាក់គុក ព្រមទាំងនាំអ្នករាល់គ្នាទៅចំពោះស្តេច នឹងចៅហ្វាយខេត្តដោយព្រោះឈ្មោះខ្ញុំផង ប៉ុន្តែការនេះនឹងត្រឡប់ប្រែជាឱកាសឲ្យអ្នករាល់គ្នាធ្វើបន្ទាល់វិញ (ម៉ាថាយ ២៤:៩ ម៉ាកុស ១៣:៩ លូកា ២១:១២-១៣) ។

## 8

ប៉ុន្តែកាលណាគេបញ្ជូនអ្នករាល់គ្នាទៅ នោះកុំឲ្យថប់ព្រួយជាមុនពីបែបនិយាយ ឬពីពាក្យដែលត្រូវថាឡើយ ត្រូវនិយាយតែសេចក្តីណាដែលបានប្រទានមកអ្នករាល់គ្នា នៅវេលានោះឯងត្បិតមិនមែនជាអ្នករាល់គ្នាដែលត្រូវនិយាយទេ គឺជាព្រះវិញ្ញាណបរិសុទ្ធទេតើ ។ (ម៉ាកុស ១៣:១១ លូកា ២១:១៤-១៥)

## 9 ការក្បត់បំពាននៅក្នុងគ្រួសារ

ប៉ុន្តែទោះទាំងឪពុកម្តាយ បងប្អូន ញាតិសន្តាន ហើយមិត្រសម្លាញ់ ក៏នឹងបញ្ជូនអ្នករាល់គ្នា ហើយនឹងសម្លាប់អ្នករាល់គ្នាខ្លះដែរ មនុស្សទាំងអស់នឹងស្អប់អ្នករាល់គ្នា ដោយព្រោះឈ្មោះខ្ញុំ តែសូម្បីតែសក់១សរសៃលើក្បាលអ្នករាល់គ្នា ក៏មិនត្រូវវិនាសបាត់បង់ផង អ្នករាល់គ្នានឹងបានជីវិតគង់នៅវិញ ដោយមានចិត្តខ្ជាប់ខ្ជួន ។ (ម៉ាថាយ ២៤:៩-១០ ម៉ាកុស ១៣:១២-១៣ លូកា ២១:១៦-១៩)

## 10 សេចក្តីស្រឡាញ់នឹងរសាយទៅអស់

ដោយព្រោះការទទឹងច្បាប់នឹងចម្រើនជាច្រើនឡើង បានជាសេចក្តីស្រឡាញ់របស់មនុស្សជាច្រើននឹងរសាយអស់ទៅ តែអ្នកណាដែលកាន់ខ្ជាប់ដល់ចុងបំផុតវិញ អ្នកនោះនឹងបានសង្គ្រោះ ។ (ម៉ាថាយ ២៤:១២-១៣)

## 11

រីឯ **ដំណឹងល្អដែលសម្តែងពីនគរព្រះ** នេះវិញ ដល់អស់ទាំងសាសន៍ **នោះទើបនឹងបាន**ដល់ចុងបំផុត ។ (ម៉ាថាយ ២៤:១៤ ម៉ាកុស ១៣:១០)

## 12 សេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញនៅក្រុងយេរូសាឡិម

ប៉ុន្តែកាលណាឃើញពលទ័ពឡោមព័ទ្ធក្រុងយេរូសាឡិម នោះត្រូវឲ្យដឹងថា សេចក្តីវិនាសនៃក្រុងនោះជិតដល់ហើយ (លូកា ២១:២០) ។ ដូច្នេះកាលណាអ្នករាល់គ្នាឃើញសេចក្តីដែលហោរាដានីយ៉ែលបានទាយទុក គឺជាសេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញ វាឈរក្នុងទីបរិសុទ្ធ (អ្នកណាដែលអានមើល ឲ្យយល់ចុះ) នោះត្រូវឲ្យពួកអ្នកដែលនៅស្រុកយូដារត់ចេញទៅឯភ្នំ កុំឲ្យអ្នកណាដែលនៅលើដំបូលផ្ទះចុះមកដើម្បីនឹងយករបស់អ្វីពីផ្ទះឡើយ ហើយកុំឲ្យអ្នកដែលនៅស្រែចម្ការត្រឡប់មកវិញ ដើម្បីនឹងយកសម្លៀកបំពាក់ខ្លួនដែរ (ម៉ាថាយ ២៤:១៥-១៨ លូកា ១៧:៣១, ២១:២១) ។ នៅគ្រានោះ ស្ត្រីណាដែលមានផ្ទៃពោះ និងស្ត្រីណាដែលបំបៅកូន នឹងវេទនាណាស់! ចូរអធិស្ឋានសូមកុំឲ្យត្រូវរត់នៅរដូវរងា ឬនៅថ្ងៃឈប់សម្រាកឡើយ (ម៉ាថាយ ២៤:១៩-២០ ម៉ាកុស ១៣:១៧-១៨ លូកា ២១:២៣) គេនឹងដួលនៅក្រោមមុខដាវ ហើយនឹងត្រូវដឹកនាំទៅជាឈ្លើយ ដល់អស់ទាំងនគរ ក្រុងយេរូសាឡិមនឹងត្រូវសាសន៍ដទៃជាន់ឈ្លីដរាបដល់គ្រាឮរបស់សាសន៍ដទៃបានសម្រេច ។ (លូកា ២១:២៤)

## 13 គ្រាវេទនារបស់ពួកយ៉ាកុប (យេរេមា ៣០:៦-៧)

ត្បិតនៅគ្រានោះ នឹងមានសេចក្តីវេទនាជាខ្លាំងណាស់ ដល់ម្ល៉េះបានជាតាំងពីដើមកំណើតលោកិយដែលទ្រង់បានបង្កើត ដរាបដល់សព្វថ្ងៃនេះ មិនដែលមានយ៉ាងដូច្នោះទេ ហើយមុខក៏មិនដែលមានផង បើព្រះអម្ចាស់ មិនបានបន្ថយថ្ងៃទាំងនោះឲ្យខ្លី នោះគ្មានមនុស្សណាបានសង្គ្រោះទេ ប៉ុន្តែទ្រង់បានបន្ថយថ្ងៃទាំងនោះ ដោយព្រោះអ្នកដែលទ្រង់បានរើសតាំង (ម៉ាថាយ ២៤:២១-២២ ម៉ាកុស ១៣:១៩-២០ លូកា ២១:២៣) ។ ត្បិតគ្រានោះជាគ្រាសងសឹក ដើម្បីនឹងសម្រេចតាមគ្រប់ទាំងសេចក្តីដែលបានចែងទុកមក ។ (លូកា ២១:២២)

## 14 ព្រះគ្រីស្ទក្លែងក្លាយ និងហោរាក្លែងក្លាយ

នៅគ្រានោះ បើមានអ្នកណាប្រាប់អ្នករាល់គ្នាថា មើល ព្រះគ្រីស្ទគង់នៅទីនេះ ឬថា មើលទ្រង់គង់នៅទីនោះ! នោះកុំឲ្យជឿឡើយ ។ ត្បិតនឹងមានព្រះគ្រីស្ទក្លែងក្លាយហើយហោរាក្លែងក្លាយកើតឡើង គេនឹងធ្វើទីសម្គាល់ព្រមទាំងការអស្ចារ្យ ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឲ្យវង្វេងផង បើសិនជាបាន ។ ប៉ុន្តែ ចូរប្រយ័ត្នឲ្យមែនទែន មើល ខ្ញុំបានប្រាប់អ្នករាល់គ្នាគ្រប់ទាំងអស់ជាមុនហើយ (ម៉ាថាយ ២៤:២៣-២៤ ម៉ាកុស ១៣:២១-២៣) ។ ដូច្នេះ បើគេប្រាប់អ្នករាល់គ្នាថា មើល ទ្រង់គង់នៅទីរហោស្ថាន! នោះកុំឲ្យចេញទៅឡើយ ឬថា មើល ទ្រង់គង់នៅក្នុងបន្ទប់! នោះក៏កុំឲ្យជឿឲ្យសោះ ព្រោះដំណើរនៃកូនមនុស្សមក នោះនឹងបានដូចជាផ្លេកបន្ទោរដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ (ម៉ាថាយ ២៤:២៦-២៧ លូកា ១៧:២៣-២៤) ។

## 15 ទីសម្គាល់នៅលើមេឃ

ត្បិតក្រោយសេចក្តីវេទនារបស់គ្រានោះមក នឹងកើតមានទីសម្គាល់ជាច្រើនដូចជា ថ្ងៃនឹងទៅជាងងឹត ខែនឹងលែងភ្លឺ អស់ទាំងផ្កាយនឹងធ្លាក់ចុះពីលើមេឃ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើករំពើក (ម៉ាថាយ ២៤:២៩ ម៉ាកុស ១២:២៤-២៥ លូកា ២១:២៥) ។ ហើយនៅលើផែនដីនឹងមានសេចក្តីទុក្ខលំបាកនៅគ្រប់ទាំងសាសន៍ និងសេចក្តីទ័លគំនិតដោយព្រោះសូរសន្ធឹករបស់សមុទ្រ មនុស្សនឹងស្រយុតចិត្តដោយភ័យ ហើយដោយទន្ទឹងចាំការដែលត្រូវមកលើផែនដី ។ (លូកា ២១:២៥-២៦)



16 នោះ**ទីសម្គាល់របស់កូនមនុស្ស** នឹងមកនៅលើមេឃ គ្រប់ទាំងពូជមនុស្សនៅលើផែនដីនឹងគក់ទ្រូងយំ ក៏នឹងឃើញកូនមនុស្សមកលើពពកនៅលើមេឃមានទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង ហើយលោកនឹងចាត់ ពួកទេវតារបស់លោកឲ្យមក ដោយសូរផ្លុំត្រែជាខ្លាំង ទេវតានោះនឹងប្រមូលពួករើសតាំងរបស់លោកពីទិសទាំងបួន ចាប់តាំង ពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង ។ (ម៉ាថាយ ២៤:៣០-៣១ ម៉ាកុស ១៣:២៦-២៧ លូកា ២១:២៧)

17 កាលណាការទាំងនេះចាប់តាំងកើតមក នោះឲ្យអ្នករាល់គ្នាងើបមើលទៅលើ ពីព្រោះសេចក្តីប្រោសលោះរបស់អ្នករាល់ជិតមកដល់ហើយ ។ (លូកា ២១:២៨)

18 រួចទ្រង់មានបន្ទូលថា "ចូររៀនពីសេចក្តីប្រៀបប្រដូចពីដើមល្វា កាលណាមែកវាត្រឡប់ជាទន់ ហើយស្លឹកក៏ប៉ិចឡើង នោះអ្នករាល់គ្នាដឹងថា រដូវក្តៅជិតមកដល់ហើយ ។ **កាលណាអ្នករាល់គ្នាឃើញការទាំងនេះកើតមក នោះត្រូវដឹងថា នគរព្រះជិតដល់ហើយ យ៉ាងដូច្នោះដែរ** ក៏នៅមាត់ទ្វារផង (ម៉ាថាយ ២៤:៣២-៣៣ ម៉ាកុស ១៣:២៨-២៩ លូកា ២១:២៩-៣១) ។ ឯត្រង់ថ្ងៃ និងពេលកំណត់ នោះគ្មានអ្នកណាដឹងបានទេ ទោះទាំងពួកទេវតាដែលនៅស្ថានសួគ៌ ឬព្រះរាជបុត្រាក៏មិនជ្រាបដែរ ជ្រាបតែព្រះវរបិតាប៉ុណ្ណោះ ។ (ម៉ាថាយ ២៤:៣៦ ម៉ាកុស ១៣:៣២)

19 ត្បិតកាលណាកូនមនុស្សមក នោះនឹងបានដូច**ជំនាន់លោកណូអេ**ដែរ ត្បិតនៅគ្រាមុនទឹកជន់លិច នោះគេកំពុងតែស៊ីផឹក ហើយរៀបការប្តីប្រពន្ធ ដរាបដល់ថ្ងៃដែលលោកណូអេចូលទៅក្នុងទូកធំ គេឥតបានដឹងខ្លួនឡើយ ទាល់តែទឹកជន់ឡើង យកគេទៅទាំងអស់គ្នា នោះដល់កាលណាកូនមនុស្សមក ក៏នឹងមានដូច្នោះដែរ ។ (ម៉ាថាយ ២៤:៣៧-៣៩ លូកា ១៧:២៦-២៧)

20 ក៏ដូចជា**ជំនាន់លោកឡុតដែរ** គេកំពុងតែផឹកស៊ី លក់ដូរ ដាំដំណាំ ហើយសង់ផ្ទះ តែនៅថ្ងៃដែលលោកឡុតចេញពីក្រុងសូដុំមមក នោះមានភ្លៀងជាភ្លើង និងស្ពាន់ធ័រ ធ្លាក់មកពីលើមេឃមកបំផ្លាញគេទាំងអស់គ្នាបង់ ។ (លូកា ១៧:២៨-៣០)

**សូមទស្សនា ANGEL TV**
**www.angeltv.org**

21 ចូរនឹកចាំពីប្រពន្ធឡុត អ្នកណាដែលចង់ឱ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ ហើយអ្នកណាដែលបាត់ជីវិត នោះនឹងនឹងបានគង់នៅវិញ ។ (លូកា ១៧:៣២-៣៣)

22 ខ្ញុំប្រាប់អ្នករាល់គ្នាថា "នៅយប់នោះ នឹងមានមនុស្សពីរនាក់ដេកនៅដំណេកជាមួយគ្នា ម្នាក់នឹងបានយកទៅ ម្នាក់នឹងត្រូវទុកនៅ និងមានស្ត្រីពីរនាក់កិនម្សៅជាមួយគ្នា ម្នាក់នឹងបានយកទៅ ម្នាក់នឹងត្រូវទុកនៅ និងមានមនុស្សពីរនាក់នៅចម្ការ ម្នាក់នឹងបានយកទៅ ម្នាក់នឹងត្រូវទុកនៅ" (ម៉ាថាយ ២៤:៤០-៤១ លូកា ១៧:៣៤-៣៦) ។ នោះពួកគេទូលសួរទ្រង់ថា "ព្រះអម្ចាស់អើយ! តើនៅឯណា?" ទ្រង់មានបន្ទូលឆ្លើយថា "ខ្មោចនៅ កន្លែងណា ឥន្ទ្រីនឹងប្រជុំគ្នានៅទីនោះឯង" ។ (ម៉ាថាយ ២៤:២៨ លូកា ១៧:៣៧)

23 **ចូរប្រុងប្រយ័ត្ន ហើយអធិស្ឋានចាំយាមជានិច្ច** នេះដូចជាមនុស្សម្នាក់ដែលចាកចោលផ្ទះចេញពីស្រុកទៅទីឆ្ងាយ ក៏ប្រគល់អំណាចដល់ពួកបាវព្រាវ ព្រមទាំងដាក់ការងារឱ្យធ្វើគ្រប់គ្នា ហើយផ្តាំអ្នកឆ្មាំទ្វារឱ្យចាំយាមផង ដូច្នេះ ចូរចាំយាមចុះ ត្បិតមិនដឹងជាវេលាណាដែលម្ចាស់ផ្ទះនឹងមកវិញទេ ទោះបើល្ងាច កណ្តាលអធ្រាត្រ ពេលមាន់រងាវ ឬព្រឹកក្តី ក្រែងលោលោកមកដល់ភ្លាម ឃើញអ្នករាល់គ្នាកំពុងតែដេកលក់ ឯសេចក្តីដែលខ្ញុំប្រាប់អ្នករាល់គ្នានេះ នោះខ្ញុំប្រាប់ដល់មនុស្សទាំងអស់ដែរ គឺថា ចូរចាំយាមចុះ ។ (ម៉ាកុស ១៣:៣៤-៣៦)

24 ចូរដឹងសេចក្តីនេះចុះ បើម្ចាស់ផ្ទះបានដឹងជាចោរនឹងមកនៅយាមណា នោះគេនឹងបានចាំយាមមិនឱ្យចោរ ទម្លុះចូលផ្ទះបានទេ ដូច្នេះឱ្យអ្នករាល់គ្នាប្រុងប្រៀបខ្លួនជាស្រេចដែរ ត្បិតកូនមនុស្សនឹងមកនៅវេលា ដែលអ្នករាល់គ្នាមិនគិត ។ (ម៉ាកុស ១៣:៣៤-៣៦)

25 ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន ក្រែងចិត្តអ្នករាល់គ្នាកំពុងតែផ្ទុកនូវសេចក្តីវក់នឹងស៊ីផឹក ហើយនិងសេចក្តីខ្វល់ខ្វាយនៅជីវិតនេះ តែថ្ងៃនោះមកដល់អ្នករាល់គ្នាភ្លាម ត្បិតថ្ងៃនោះនឹងមកដូចជាលប់ គ្របលើអស់ទាំងមនុស្សដែលនៅគ្រប់លើផែនដី ។ (ម៉ាកុស ១៣:៣៣ លូកា ២១:៣៤-៣៥)

អាសយដ្ឋានទំនាក់ទំនងក្នុងប្រទេស

26 សេចក្តីដែលខ្ញុំប្រាប់ដល់អ្នករាល់គ្នានេះ នោះខ្ញុំក៏ប្រាប់ដល់មនុស្សទាំងអស់ដែរគឺថា "ចូរចាំយាមចុះ ហើយអធិស្ឋាន ជានិច្ច ដើម្បីឱ្យបានរាប់ជាគួរនឹងរួចពីការទាំងនេះដែលត្រូវមក ហើយឱ្យបានឈរនៅមុខកូនមនុស្សផង ។ (លូកា ២១:៣៦)

27 ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មនុស្សតំណនេះនឹងមិនទាន់កន្លងហួសបាត់ទៅឡើយ ទាល់តែគ្រប់ការទាំងនោះបានកើតមកឯផ្ទៃមេឃ និងផែនដី នោះនឹងកន្លងបាត់ទៅ តែឯពាក្យខ្ញុំមិនដែលកន្លងបាត់ឡើយ ។ (ម៉ាថាយ ២៤:៣៤-៣៥ លូកា ២១:៣២-៣៣)

**ព្រះមហាក្សត្រដ៏មហិមា**
**ទ្រង់គង់នៅលើបល្ល័ង្កដ៏រុងរឿងរបស់ទ្រង់**
**ព្រះអម្ចាស់យេស៊ូវគ្រីស្ទនឹងយាងត្រឡប់មកវិញ**
**ប្រកបដោយព្រះចេស្តា និងសិរីរុងរឿងដ៏អស្ចារ្យ**
**ព្រមទាំងហែរហមដោយ ពួកទេវតាដ៏បរិសុទ្ធ**
**និងពួកបរិសុទ្ធរបស់ទ្រង់ផង ។**

**ចូរកោតខ្លាចដល់ព្រះ ហើយសរសើរសិរីល្អ**
**របស់ទ្រង់ចុះ ត្បិតពេលទ្រង់ត្រូវជំនុំជម្រះ**
**នោះបានមកដល់ហើយ ចូរក្រាបថ្វាយបង្គំ**
**ដល់ព្រះដ៏បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ**
**និងរន្ធទឹកទាំងប៉ុន្មានផង**
(វិវរណៈ ១៤:៧)

**ពេលវេលាមិនបង្អង់ទៀតឡើយ!**

**ពេលនេះនគរព្រះមកជិតបង្កើត**
**ចូរប្រែចិត្ត ហើយជឿលើដំណឹងល្អនេះចុះ!**

**ចូរប្រុងប្រៀបខ្លួន ដើម្បីជួបព្រះអម្ចាស់**
**ជាព្រះរបសអ្នករាល់គ្នាចុះ!**



# ដំណឹងល្អ ដែលសម្តែងពីនគរព្រះ

ភាសាខ្មែរ | KHMER